# ការពិនិត្យជាសកលតាមកាលកំណត់សម្រាប់ប្រទេសកម្ពុជា

## ដំណាក់កាលនៃការអនុវត្ត

- ការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិដែលពិនិត្យលើការប្រតិបត្តិរបស់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិនីមួយៗ ចំពោះកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋនីមួយៗ។
- ក្នុងអំឡុងពេល UPR រដ្ឋជាសមាជិកអង្គការសហប្រជាជាតិផ្តល់អនុសាសន៍នានាទៅដល់រដ្ឋត្រូវទទួលការត្រួតពិនិត្យដែលអាចធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សបានល្អប្រសើរឡើង។




## ដំណើរការពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទី៣ របស់ប្រទេសកម្ពុជា

លទ្ធផលនៃការពិនិត្យជាសកលតាមកាលកំណត់ជុំទី៣ នៃប្រទេសកម្ពុជា ឆ្នាំ២០១៩៖

- ក្នុងខែមករា ឆ្នាំ២០១៩ **ប្រទេសកម្ពុជាបានទទួលនូវអនុសាសន៍សរុបចំនួន១៩៨** ពីរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន៧៣ ទាក់ទងនឹងបញ្ហាផ្នែកសិទ្ធិមនុស្សផ្សេងៗ។
- ក្នុងខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានទទួលយក**អនុសាសន៍ចំនួន ១៧៣**។

- ទាក់ទងនឹងបញ្ហាផ្នែកសិទ្ធិមនុស្សផ្សេងៗជាច្រើន ដូចជា សិទ្ធិដីធ្លី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការការពារដល់អ្នកការពារសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី និងសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (សូជី) ជាដើម។

- រាជរដ្ឋាភិបាលកម្ពុជាបានកត់សម្គាល់**អនុសាសន៍ចំនួន ២៥**

- ទាក់ទងនឹងសេរីភាពមូលដ្ឋាន សេរីភាពព័ត៌មាននិង ការដោះលែងអ្នកទោសនយោបាយ។


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org



BY NC SA


កញ្ញា ២០១៩

# ដំណាក់កាលបន្ទាប់ ៖ ការអនុវត្តអនុសាសន៍

➡ ការអនុវត្តអនុសាសន៍គឺជាគោលបំណងចុងក្រោយនៃដំណើរការ UPR ដើម្បីឱ្យមានការគោរពសិទ្ធិមនុស្សល្អប្រសើរនៅកម្ពុជា

## តួនាទីរបស់ដៃគូផ្សេងៗក្នុងដំណាក់កាលអនុវត្ត



### រាជរដ្ឋាភិបាលកម្ពុជា



- ✓ តាក់តែងគោលនយោបាយ។
- ✓ បង្កើតច្បាប់។
- ✓ ប្រឹក្សាយោបល់ និងសហការជាមួយសង្គមស៊ីវិល។
  - ➡ ប្រឹក្សាយោបល់ដោយបរិយាប័ន្ន ប្រកបដោយអត្ថន័យនិងជាទៀងទាត់ ដើម្បីធ្វើបច្ចុប្បន្នអំពីវឌ្ឍនៈភាព និងស្វែងរកការពិគ្រោះយោបល់លើបញ្ហាជាក់លាក់។
- ✓ បង្កើតយន្តការថ្នាក់ជាតិដើម្បីរាយការណ៍ និងតាមដាន
  - ➡ សម្របសម្រួលនិងប្រឹក្សាយោបល់ជាអចិន្ត្រៃយ៍នៅគ្រប់ក្រសួងនិងជាមួយដៃគូពាក់ព័ន្ធទាំងអស់(សង្គមស៊ីវិល ភ្នាក់ងារអង្គការសហប្រជាជាតិ សភា និងតុលាការ)។
- ✓ បង្កើតផែនការសកម្មភាពផ្នែកសិទ្ធិមនុស្សដើម្បីកំណត់ក្រសួងដែលទទួលខុសត្រូវចំពោះការអនុវត្ត**បង្កើតសូចនាករ**ដើម្បីវាស់វែងលើការអនុវត្ត។

### ប្រជាពលរដ្ឋកម្ពុជាទូទៅ

- ✓ អាចចូលរួមកិច្ចសន្ទនាជាសាធារណៈជុំវិញដំណើរការ UPR អនុសាសន៍ និងបញ្ហាសិទ្ធិមនុស្ស ដែលទាក់ទងនឹងអនុសាសន៍ទាំងនោះ។
- ✓ អាចជួយតាមដានលើការអនុវត្តអនុសាសន៍។
- ✓ លើកទឹកចិត្តដល់សាធារណជនក្នុងការជំរុញឱ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ដែលបានទទួលយកទាំងនោះ។



### សង្គមស៊ីវិល

= អង្គការសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស សហជីព អង្គការនៅមូលដ្ឋាន។

- ✓ អាចជួយនិងសហការជាមួយដៃគូពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមនិងគាំទ្រអនុវត្តអនុសាសន៍។
  - ➡ ផ្តល់យោបល់ដល់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សជាក់លាក់។
  - ➡ តស៊ូមតិអំពីបញ្ហាសិទ្ធិមនុស្សដែលផ្អែកលើអនុសាសន៍នានា។
- ✓ អាចឃ្លាំមើល និងរាយការណ៍អំពីការអនុវត្តអនុសាសន៍។



### រដ្ឋដែលផ្តល់អនុសាសន៍

= រដ្ឋជាសមាជិកអង្គការសហប្រជាជាតិដែលផ្តល់អនុសាសន៍ដល់កម្ពុជានៅជុំទី៣។

- ✓ បន្តកិច្ចសន្ទនាទ្វេរភាគីជាមួយរដ្ឋាភិបាល។
  - ➡ ស្នើសុំព័ត៌មានលម្អិតបន្ថែមទាក់ទងនឹងផែនការអនុវត្តដែលនេះក៏អាចផ្តល់ជំនួយបច្ចេកទេសផងដែរ។
  - ➡ អនុសាសន៍នានាអាចបង្កើតជាមូលដ្ឋាននៃការពិភាក្សារវាងរដ្ឋដែលផ្តល់អនុសាសន៍និងរដ្ឋដែលត្រូវទទួលការពិនិត្យដូចជាក្នុងពេលកិច្ចសន្ទនាសិទ្ធិមនុស្សទ្វេរភាគីជាដើម។
- ✓ គាំទ្រសង្គមស៊ីវិលនៅកម្ពុជា។
  - ➡ ផ្នែកហិរញ្ញវត្ថុ (គាំទ្រសង្គមស៊ីវិលធ្វើយុទ្ធនាការតស៊ូមតិ និងតាមដានការអនុវត្តអនុសាសន៍)។
  - ➡ ចូលរួមដល់កិច្ចការពារលំហសង្គមស៊ីវិលដើម្បីធានាថាអង្គការសង្គមស៊ីវិលមានសេរីភាពក្នុងការអនុវត្តសកម្មភាពការងារទាក់ទងនឹង UPR ដោយជួយការពារអង្គការសង្គមស៊ីវិលទាំងនោះពីផលវិបាកនានាដែលកើតឡើងដោយសារការងាររបស់ពួកគេ។
- ✓ តាមដាន និងរាយការណ៍ អំពីការអនុវត្តអនុសាសន៍។

សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការពិនិត្យជាសកលតាមកាលកំណត់របស់ប្រទេសកម្ពុជានៅជុំទី៣ សូមចូលទៅកាន់គេហទំព័រ sithi.org/upr

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org

CC BY NC SA